# កម្ពុជាដើម្បីកុមារ

## ការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាដើម្បីកុមារ

បន្ទាប់ពីសង្គ្រាមដែលបណ្តាលឱ្យមានភាពខ្ទេចខ្ទាំអស់រយៈពេលជាងពីរទសវត្សប្រទេសកម្ពុជាបានឈានចូលទៅក្នុងយុគសម័យមួយដែលមានសន្តិភាពពេញលេញ និងមានស្ថេរភាព។ កម្ពុជាកំពុងកសាងជាបណ្តើរៗនូវហេដ្ឋានចនាសម្ព័ន្ធដែលបានខូចខាត និងកសាងសមត្ថភាពរបស់ខ្លួនដើម្បីរួម និងធ្វើវិនិយោគទៅក្នុងកិច្ចអភិវឌ្ឍន៍ ។រាជរដ្ឋាភិបាលក៏ទទួលស្គាល់ផងដែរថានៅមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីឈានទៅសំរេចគោលដៅដែលជាអនាគតដ៏ភ្លឺស្វាងរបស់ប្រជាជនកម្ពុជាទាំងមូល។

ទោះបីកន្លងមក រាជរដ្ឋាភិបាលបានខិតខំធ្វើឱ្យមានការរីកចំរើនលើគ្រប់វិស័យយ៉ាងណាក៏ដោយក៏នៅមានកុមារជាច្រើនបានស្លាប់មុនអាយុប្រាំឆ្នាំដោយសារកង្វះអាហារូបត្ថម្ភ និងដោយសារជម្ងឺ។ កុមារមួយចំនួនទៀតពុំទាន់បានទទួលនូវការថែទាំសុខភាពគ្រប់គ្រាន់ និងពុំទាន់ទទួលបាននូវការអប់រំមូលដ្ឋានប្រកបដោយគុណភាព កុមារខ្លះរស់នៅតាមចិញ្ចើមថ្នល់ កុមារខ្លះប្រើគ្រឿងញៀនខ្លះជាកុមារកំព្រាខ្លះជាកុមារមានជំងឺអេដស៍ហើយនៅមានកុមារខ្លះទៀតធ្លាក់ខ្លួនរងគ្រោះដោយការជួញដូរ និងកេងប្រវ័ញ្ច ។

ទន្ទឹមនឹងកិច្ចការជាច្រើនដែលត្រូវធ្វើប្រទេសកម្ពុជាប្តេជ្ញាធានាលើកកំពស់ដល់សុខុមាលភាព និងការអភិវឌ្ឍន៍របស់កុមារទាំងអស់។

## ក. ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅលើសកលលោក និង ក្នុងតំបន់ដើម្បីកុមារ

នៅសន្និសីទកំពូលពិភពលោកដើម្បីកុមារឆ្នាំ ១៩៩០ ថ្នាក់ដឹកនាំនៃប្រទេសក្នុងពិភពលោកបានប្តេជ្ញាចិត្តថា និងបង្កើនសុខុមាលភាពរបស់កុមារឱ្យកាន់តែប្រសើរឡើង ព្រមទាំងបានចេញសេចក្តីអំពាវនាវជាសកលនិងជាបន្ទាន់ក្នុងគោលបំណងធានានូវអនាគតដ៏ល្អប្រសើរសំរាប់កុមារទាំងអស់។ ការប្តេជ្ញាចិត្តនេះត្រូវបានអះអាងជាថ្មីម្តងទៀតក្នុងសម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិស្តីពីកុមារនៅខែឧសភា ឆ្នាំ ២០០២ ។ ឯកសារ " **ពិភពលោកសមស្របសំរាប់កុមារ** " គឺជាក្របខ័ណ្ឌការងារដែលរដ្ឋាភិបាល និងដៃគូរបស់ខ្លួនទាំងអស់ព្រមទាំងកុមារខ្លួនឯងផង នឹងប្រើប្រាស់ដើម្បីសំរេចគោលដៅ និងដោះស្រាយការលំបាកដែលកំពុងកើតមានចំពោះកុមារ។ ឯកសារ " **ពិភពលោកសមស្របសំរាប់កុមារ** " បានគូសបញ្ជាក់នូវបញ្ហាអាទិភាពចំនួន៤ ដើម្បីបង្កើនជីវភាពរស់នៅរបស់ស្ត្រី និងកុមាររួមមានការបង្កើនជីវភាពរស់នៅប្រកបដោយសុខភាពល្អការបង្កើនគុណភាពអប់រំការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និង ជម្ងឺអេដស៍ កិច្ចការពារកុមារពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងអំពើហឹង្សា ។

តាំងពីឆ្នាំ ១៩៩០ ប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ា និង ប៉ាស៊ីហ្វិកបានប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីចំនួន ៦លើក ដើម្បីពិនិត្យឡើងវិញនូវការរីកចំរើនដែលសំរេចបានសំរាប់កុមារដោយបានចែករំលែកបទ

ពិសោធន៏ល្អៗព្រមទាំងកំណត់គោលដៅសំរាប់អនាគត។ កិច្ចប្រជុំពិគ្រោះយោបល់ដែលបានប្រារព្ធឡើងនៅកោះបាលីប្រទេស ឥណ្ឌូនេស៊ី កាលពីថ្ងៃទី ៥-៧ ខែឧសភា ឆ្នាំ ២០០៣ ថ្មីៗនេះ ដែលមានគណៈប្រតិភូនៃប្រទេសកម្ពុជា និង ប្រទេស ២២ ផ្សេងទៀតនៅក្នុងតំបន់ចូលរួមបានអះអាងឡើងវិញអំពីគោលដៅសកលលោកដើម្បីកុមារ និងបានឯកភាពលើបញ្ហាជាអាទិភាពក្នុងតំបន់។ បញ្ហាអាទិភាពទាំងនេះត្រូវបានចែងនៅក្នុង "កិច្ចព្រមព្រៀងបាលីស្តី ពីភាពជាដៃគូជាមួយកុមារ និងដើម្បីកុមារ" ក្នុងនោះមានបញ្ហាមេរោគអេដស៏ និងជម្ងឺអេដស៏ ការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ មរណៈភាពរបស់មាតា និងទារក និងកង្វះអាហារូបត្ថម្ភ។

## ខ.ការប្រែក្លាយគោលដៅសកល និង តំបន់នៅជាសកម្មភាពជាតិដើម្បីកុមារ

កិច្ចព្រមព្រៀងកោះបាលី ឯកសារពិភពលោកសមស្របសំរាប់កុមារ ការប្តេជ្ញាចិត្តនានារបស់តំបន់ និងជាសកលនិង គោលដៅដែលគួរឱ្យកត់សំគាល់បំផុតនោះគឺ "សេចក្តីប្រកាសសហសវត្សរ៏និង "គោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏" ដែលត្រូវបានអនុម័តដោយសន្និបាតនៃអង្គការសហប្រជាជាតិ បានផ្តល់នូវមូលដ្ឋានគ្រឹះ សំរាប់របៀបវារៈអន្តរជាតិថ្មីមួយដើម្បីកុមារ ។

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចូលគ្នានូវរបៀបវារៈថ្មីដើម្បីកុមារនេះហើយធ្វើអោយមានទិសដៅជាក់លាក់និងគោរដៅដែលមានពេលកំណត់។ ដើម្បីឈានទៅដល់គោលដៅទាំងនេះយើងត្រូវធានាថា ការប្តេជ្ញាចិត្តជាសកល និងតំបន់ត្រូវបានឆ្លុះបញ្ចាំងទាំងស្រុងទៅនឹងបណ្តាលអាទិភាពថ្នាក់ជាតិដោយបញ្ចូលគោលដៅទាំងនោះទៅក្នុងផែនការសកម្មភាពក្របខ័ណ្ឌការងារ និងយុទ្ធសាស្រ្តដែលមានស្រាប់។ ជាក់ស្តែងកិច្ចការទាំងអស់នេះកំពុងត្រូវបាន អនុវត្តយ៉ាងល្អ ដោយមានបញ្ចូលបញ្ហាកុមារទៅក្នុងផែនការយុទ្ធសាស្រ្ត និងគោលនយោបាយជាតិដែលមានស្រាប់រួមមានៈ

- យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥
- អប់រំសំរាប់ទាំងអស់គ្នា/ ផែនការយុទ្ធសាស្រ្តអប់រំ /កម្មវិធីគាំទ្រវិស័យអប់រំ២០០២-២០០៦
- ផែនការយុទ្ធសាស្រ្តវិស័យសុខាភិបាល ២០០៣-២០០៧
- ផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាល នៃជម្ងឺអេដស៏ ២០០១-២០០៥
- ផែនការជាតិប្រាំឆ្នាំការជួញដូរ និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២០០០-២០០៤
- ផែនការវិនិយោគអាហាររូបត្ថកម្ពុជា២០០៣-២០០៧
- គោលនយោបាយជាតិប្រជាជន ២០០៣
- គោលដៅ អភិវឌ្ឍន៏សហវត្សរ៏កម្ពុជា ២០០៣

## គ.ការប្តេជ្ញាចិត្តដើម្បីកុមារ

ផ្អែកតាមផែនការយុទ្ធសាស្ត្រជាតិ និង គោលនយោបាយជាតិខាងលើរាជរដ្ឋាភិបាលបានធ្វើឱ្យសំរេចនូវការរីកចំរើនមួយចំនួនសំរាប់កុមារ ប៉ុន្តែចំពោះមុខនៅមានកិច្ចប្រឹងប្រែងជាច្រើនទៀតដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ ប្រទេសកម្ពុជាសូមស្វាគមន៍ចំពោះការប្តេជ្ញាចិត្ត " ពិភពលោកសមស្របសំរាប់កុមារ និងកិច្ចព្រមព្រៀងកោះបាលី " ដែលជាកិច្ចខិតខំប្រឹងប្រែងរួមសំរាប់ដៃគូរទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ក្នុងកិច្ចសហការជាមួយដៃគូសំខាន់ទាំងនេះរួមមានស្ថានប័នថ្នាក់កណ្តាល និង ថ្នាក់ខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អង្គការថ្នាក់តំបន់និង អង្គការអន្តរជាតិ អ្នកផ្តល់ជំនួយ ហើយសំខាន់បំផុតនោះគឺកុមារ និងយុវជនខ្លួនឯង ។ រាជរដ្ឋាភិបាលនឹងខ្នះខ្នែង ការពារ និង បង្កើនសុខុមាលភាពរបស់កុមារ ដោយផ្តោតលើបញ្ហាអាទិភាពដូចខាងក្រោម:

### ១. ការកាត់បន្ថយអត្រាមរណៈភាពរបស់មាតា និង ទារក

- ការផ្តល់វ៉ាក់សាំងការពារជម្ងឺ
- ការទប់ស្កាត់កង្វះមីក្រូសារជាតិ ( ជាតិអ៊ីយ៉ូដ និង វីតាមីនអា )
- ការទំលាក់ព្រូន
- ការអនុវត្តន៏វិធីផ្តល់ចំណីអាហារដល់ទារក និងកុមារ រួមមានការបំបៅដោយទឹកដោះម្តាយទាំង-ស្រុង និងបំបៅទឹកដោះម្តាយនៅពេលទារកកើតមកភ្លាម
- លទ្ធភាពអាចទទួលសេវាថែទាំបន្ទាន់ផ្នែកសម្ភព និងសេវាពន្យាកំណើត។

### ២. ការអប់រំប្រកបដោយគុណភាព និង ការកាប់បន្ថយគម្លាតយេនឌ័រ

- លទ្ធផលនៃការសិក្សា ជាពិសេសអក្សរសាស្ត្រ លេខនព្វន្តនិង បំណិនជីវិត
- គម្លាតយេនឌ័រ សេដ្ឋកិច្ច - សង្គម និង ការចុះឈ្មោះចូលរៀនបឋមសិក្សានៅទីក្រុង/ជនបទ
- តុល្យភាពយេនឌ័រ សេដ្ឋកិច្ច-សង្គមនិង ភូមិសាស្ត្រ ក្នុងការចុះឈ្មោះចូលរៀននៅថ្នាក់ទី៧ដល់ថ្នាក់ទី៩
- ការបង្កើនការអប់រំក្រៅប្រព័ន្ធ ជាពិសេសដល់កុមារពលករ
- ការបង្កើនភាពត្រៀមជាស្រេចរបស់កុមារកម្ពុជាអោយចូលសិក្សានៅអាយុ ៦ឆ្នាំ ។

### ៣. ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជម្ងឺអេដស៍

- យុវជននៅក្នុងភាពងាយទទួលរងគ្រោះ
- ការព្យាបាល និង ការថែទាំ
- កុមារកំព្រាដោយមេរោគអេដស៍ និង ជំងឺអេដស៍ ។

## ៤.កិច្ចការពារកុមារជាពិសេសប្រឆាំងការជួញដូរ ការកេងប្រវ័ញ្ច និង ការរំលោភបំពាន

- ការរៀបចំប្រព័ន្ធការងារដើម្បីធានាដល់ការចុះបញ្ជីជាតិសំរាប់កុមារគ្រប់ៗរូប នៅពេលសំរាលឬ ក្នុងរយៈពេលខ្លីក្រោយពេលសំរាល
- កិច្ចការពារស្របច្បាប់ប្រឆាំងនិងការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទនិង ការបំពារបំពាន
- កិច្ចការពារកុមារតាមផ្លូវច្បាប់ តាមរយៈប្រព័ន្ធយុត្តិធម៌សំរាប់កុមារ
- ផែនការសកម្មភាពប្រឆាំងនិងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ផែនការជាតិថ្មី ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ រួមមានការពិនិត្យតាមដាននិងយន្តការដើម្បីអនុវត្ត
- វិធានការកិច្ចបង្ការការស្តាសមត្ថភាព និងសមាហរណកម្មកុមារ ដែលងាយទទួលរងគ្រោះ និងកុមារជាជនរងគ្រោះ
- វិធានការការពារកុមារពិការ ។

## ឃ. ការពិនិត្យតាមដាន និង ការធ្វើរបាយការណ៍អំពីការរីកចំរើន

ការពិនិត្យតាមដានលើបញ្ហាអាទិភាពទាំងនេះដើម្បីកុមារ នឹងត្រូវអនុវត្តយ៉ាងទូលំទូលាយក្នុងក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតំលៃលើផែនការដែលមានស្រាប់តាមផ្នែកនីមួយៗ។ សកម្មភាពនៃការប្រមូលទិន្នន័យបន្តទៀត និងត្រូវបានសំរេចសំរួលតាមរយៈវិទ្យាស្ថានជាតិស្ថិតិដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងមន្ទីរ តាមលំដាប់ថ្នាក់ដែលពាក់ព័ន្ធ។ សកម្មភាពចម្បងពីរក្នុងការប្រមូលទន្ន័យដែលនឹងជួយយើងដើម្បីវាស់ស្ទង់ការរីកចំរើននោះគឺការអង្កេតសេដ្ឋកិច្ច - សង្គមកិច្ចគ្រួសារ ២០០៣-២០០៤ និងអង្កេតចន្លោះជំរឿន ២០០៤។ ទិន្នន័យអំពីកុមារនឹងត្រូវបានគ្រប់គ្រង និង ផ្សព្វផ្សាយតាមរយៈខេមអ៊ិនហ្វូ (CamInfo) មូលដ្ឋានទិន្នន័យ សូចនាករជាតិ និងតាមរយៈ (TSECInfo) សូចនាករនៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។ ក.ជ.ក.ក.នឹងធ្វើប័ណ្ណរបាយការណ៍ប្រចាំឆ្នាំស្តីពីការរីកចំរើនដែលទទួលបានដោយផ្តោតលើបណ្តាលអាទិភាពដែលមាននៅក្នុងឯកសា " កម្ពុជាដើម្បីកុមារ " ។

## ង. តួនាទីរបស់កុមារ និង យុវជន

ឯកសាពិភពលោកសមស្របសំរាប់កុមារ និងកិច្ចព្រមព្រៀងកោះបាលី គឺជាគោលការណ៍រួមនៃការចូលរួមរបស់កុមារ និងយុវជន។ ប្រទេសកម្ពុជាទទួលស្គាល់ថា ជោគជ័យនៃកិច្ចប្រឹងប្រែងដើម្បីបង្កើនជីវភាពរស់នៅរបស់កុមារ គឺផ្អែកលើភាពរឹងមាំនៃភាពជាដៃគូ ដែលយើងប្រឹងប្រែងធ្វើជាមួយ និងដើម្បីកុមារ និងយុវជន ក៏ដូចជាទំហំនៃការផ្តល់ឱ្យពួកគេចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ។

ប្រទេសកម្ពុជាប្តេជ្ញាបង្កើនការចូលរួមយ៉ាងសកម្ម និង ប្រកបដោយអត្ថន័យរបស់កុមារនិង យុវជន និង-ផ្តល់ សិទ្ធិអោយពួកគេបានចូលរួមធ្វើអោយបានសំរេចតាមឯកសារ " កម្ពុជាដើម្បីកុមារ " ។ ប្រទេសកម្ពុជា

ទទួលស្គាល់ថា បើគ្មានការយល់ដឹងជ្រៅជ្រះ និងការរួមវិភាគទានដ៏មានតំលៃរបស់ពួកគេទេនោះក៏សិទ្ធិរបស់កុមារពុំមានការរីកចំរើនប្រកបដោយនិរន្តភាពឡើយ ។ យើងនឹងពុះពារអភិវឌ្ឍន៏បន្ថែមទៀតនូវសមត្ថភាពរបស់កុមារ និងយុវ ជនកម្ពុជា ដើម្បីរួមចំណែកក្នុងគ្រួសារ សាលារៀន សហគមន៏ តាមរយៈបង្កើនការអប់រំការអភិវឌ្ឍន៏ជំនាញ និងបណ្ដុះបណ្ដាលកីឡា និងសិល្បៈ ។ យើងនឹងបង្កើតអោយមានបរិយាកាសប្រកបដោយលទ្ធភាព និង ការគាំទ្រ ដែលសំលេង និងមតិរបស់កុមារ និងត្រូវបានគេយកចិត្តទុកដាក់ស្ដាប់ និងអនុវត្តតាម ។